01169881

E319/31/2

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 12 / 11 / 2015
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent charge du dossier: Sann Rada

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# អង្គជំនុំជម្រះសាលាដំបូង

សាធារណៈ / Public

កាលបរិច្ឆេទ: ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១៥

**ជូនចំពោះ៖** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** សេចក្តីសម្រេចលើសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំឱ្យទទួលយកជាភស្តុតាងនូវទម្រង់ព័ត៌មានជនរងគ្រោះ និងឯកសារពាក់ព័ន្ធ

១. អង្គជំនុំជម្រះសាលាដំបូង បានទទួលសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី (សហមេធាវីនាំមុខ) ស្នើសុំឱ្យទទួលយកជាភស្តុតាងនូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួនពីរ (ឯកសារ E319/25.3.24, ឯកសារ E319/27.4.109) និងឯកសារពាក់ព័ន្ធ ដោយអនុលោមតាមវិធាន ៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង (ឯកសារ E319/31)។ សហមេធាវីនាំមុខអះអាងថា ចម្លើយទាំងនេះមានប្រយោជន៍ ក្នុងការស្វែងរកការពិត ហើយពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ និងស្របទៅនឹងសេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការដាក់បង្ហាញពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីពីសំណុំរឿង ០០៣ និង ០០៤ (ឯកសារ E319/31, កថាខណ្ឌ ៣)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះត្រូវបានដាក់ជូនអង្គភាពគាំពារជនរងគ្រោះក្រោយពេលបើកការជំនុំជម្រះ

នៅក្នុងខែ មិថុនា ឆ្នាំ ២០១១ ប៉ុន្តែទើបតែត្រូវបានដាក់បង្ហាញដល់សហមេធាវីនាំមុខ និងភាគីកាលពីថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៥ ប៉ុណ្ណោះ (ឯកសារ E319/31, កថាខណ្ឌ ៥)។ នៅក្នុងសវនាការនាថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៥ សហមេធាវីនាំមុខបានបញ្ជាក់បំភ្លឺថា ខ្លួនលែងស្នើសុំសំអាងទៅលើឯកសារ E319/25.3.24 ទៀតហើយ ដោយហេតុថាឯកសារនេះ គឺជាកម្មសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីមួយរូប ដែលការផ្តល់សក្ខីកម្មរបស់គាត់ត្រូវបានលុបចោលហើយទុកឱ្យអង្គជំនុំជម្រះសាលាដំបូងជាអ្នកសម្រេច ថាតើឯកសារនេះគួរត្រូវបានទទួលយកជាភស្តុតាងដែរឬយ៉ាងណា (ប្រតិចារឹក ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៥, ទំព័រ ៣-៤)។

២. មេធាវីការពារក្តី ខៀវ សំផន ជំទាស់ទៅនឹងការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយច្បាប់ (ឯកសារ E319/25.3.24) ដែលជារបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលការផ្តល់សក្ខីកម្មរបស់គាត់ត្រូវបានលុបចោល (ឯកសារ E319/31/1, កថាខណ្ឌ ២,៣,៦)។ មេធាវីការពារក្តី ខៀវ សំផន អះអាងថាមានតែឯកសារដែលដោះបន្ទុក ឬ ដែលអាចប៉ះពាល់ដល់ភាពជឿជាក់បាននៃភស្តុតាងដាក់បន្ទុក ព្រមទាំងចម្លើយមុនៗរបស់បុគ្គលដែលផ្តល់សក្ខីកម្មប៉ុណ្ណោះ គួរត្រូវបានដាក់បង្ហាញ។ ហេតុនេះ មេធាវីការពារក្តី ខៀវ សំផន អះអាងថាឯកសារ E319/25.3.24 ត្រូវបានដាក់បង្ហាញដោយមិនស្របច្បាប់ ហើយពុំគួរត្រូវបានទទួលយកជាភស្តុតាងឡើយ (ឯកសារ E319/31/1, កថាខណ្ឌ ៤-៥)។

៣. អង្គជំនុំជម្រះធ្លាប់បានបដិសេធអំណះអំណាងរបស់មេធាវីការពារក្តី ខៀវ សំផន ដែលថាការដាក់បង្ហាញឯកសារពីសំណុំរឿង ០០៣ និង ០០៤ គឺមិនស្របច្បាប់ ដោយបានកត់សម្គាល់ថាការដាក់បង្ហាញឯកសារបន្ថែមពីលើឯកសារទាំងឡាយដែលស្ថិតនៅក្រោមភារកិច្ចដាក់បង្ហាញរបស់សហព្រះរាជអាជ្ញា "ពុំមែនជាការរំលោភសិទ្ធិរបស់ជនជាប់ចោទឡើយ [...] ដរាបណាមានការផ្តល់ឱ្យនូវមធ្យោបាយសមស្របក្នុងការពិនិត្យមើលឯកសារទាំងនោះ" (ឯកសារ E363/3, កថាខណ្ឌ ៣១)។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ចាប់តាំងពីថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៥ ដែលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះត្រូវបានដាក់បង្ហាញ មេធាវីការពារក្តីមានពេលវេលា និង មធ្យោបាយគ្រប់គ្រាន់ដើម្បីស្វែងយល់អំពីឯកសារទាំងនេះ។ ហេតុដូចនេះ បញ្ហាចំពោះមុខនៅពេលនេះពុំមែនថាតើឯកសារទាំងនេះត្រូវបានដាក់បង្ហាញដោយត្រឹមត្រូវ ឬ យ៉ាងណានោះឡើយ ប៉ុន្តែគឺថាតើឯកសារទាំងនេះគួរត្រូវបានទទួលយកអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ដែរ ឬ យ៉ាងណា។

៤. យោងតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង នៅគ្រប់ដំណាក់កាលនៃការជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូងអាចទទួលយកភស្តុតាងទាំងអស់ ដែលខ្លួនយល់ថាមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត (ឯកសារ E319/7, កថាខណ្ឌ ៨)។ អង្គជំនុំជម្រះនឹងធ្វើសេចក្តីសម្រេចចំពោះការស្នើសុំនោះ ផ្អែកតាមខ្លឹមសារដែលមានចែងនៅក្នុងវិធាន ៨៧(៣)។ វិធាន ៨៧(៤) ក៏បានតម្រូវដែរថា គ្រប់ភាគីដែលស្នើសុំឱ្យអង្គជំនុំជម្រះទទួលយកភស្តុតាងថ្មី ត្រូវបញ្ជាក់មូលហេតុនៃការស្នើសុំនេះឱ្យបានច្បាស់លាស់។ ភាគីស្នើសុំត្រូវតែធ្វើឱ្យអង្គជំនុំជម្រះជឿជាក់ថា ភស្តុតាងដែលបានស្នើសុំនោះ ពុំអាចរកបាននៅមុនពេលការចាប់ផ្តើមជំនុំជម្រះ ឬមិនអាចរកបានបន្ទាប់ពីការបំពេញការងារដោយយកចិត្តទុកដាក់ក៏ដោយ។ ទោះជាយ៉ាងនេះក្តី ក្នុងករណីមួយចំនួន អង្គជំនុំជម្រះធ្លាប់បានទទួលយកភស្តុតាងដែលមិនបានបំពេញតាមលក្ខខណ្ឌតម្រូវនេះទាំងស្រុងទេ រួមមាន ក្នុងករណីដែលភស្តុតាងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងសម្ភារៈដែលមាននៅចំពោះមុខអង្គជំនុំជម្រះរួចហើយ ហើយផលប្រយោជន៍នៃយុត្តិធម៌តម្រូវឱ្យវាយតម្លៃប្រភពទាំងនោះរួមគ្នា នៅពេលដែលភស្តុតាងដែលបានស្នើសុំនោះជាភស្តុតាងដោះបន្ទុក និង តម្រូវឱ្យមានការវាយតម្លៃដើម្បីជៀសវាងកុំឱ្យមានកំហុសក្នុងការស្វែងរកយុត្តិធម៌ ឬ នៅពេលដែលភាគីផ្សេងទៀតមិនជំទាស់ទៅនឹងភស្តុតាងនោះ (ឯកសារ E276/2, កថាខណ្ឌ ២ ដោយយោងដល់ឯកសារ E190 និងឯកសារ E172/24/5/1)។

៥. អង្គជំនុំជម្រះសង្កេតឃើញថាពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២ ច្បាប់ ដែលជាបញ្ហានាពេលនេះ ត្រូវបានទទួលយកដោយអង្គភាពគាំពារជនរងគ្រោះក្នុងខែ កក្កដា ឆ្នាំ ២០១៣ និងត្រូវបានដាក់បង្ហាញទៅសហមេធាវីនាំមុខ និងភាគីនៅថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៥។ ហេតុដូចនេះ ឯកសារទាំងនេះមិនអាចរកបានមុនពេលចាប់ផ្តើមការជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ ក្នុងខែ មិថុនា ឆ្នាំ ២០១១ និងត្រូវបានដាក់ជូនអង្គជំនុំជម្រះបានទាន់ពេលវេលា។

៦. ឯកសារ E319/27.4.109 គឺជាពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ឈ្មោះ មាន លឿយ ដែលបានមកផ្តល់សក្ខីកម្មនៅក្នុងសវនាការនៅថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១៥ ស្តីពីព្យសនកម្មដែលបានទទួលរង លើអង្គហេតុទំនប់ត្រពាំងថ្ម។ ហេតុដូចនេះ ឯកសារនេះពាក់ព័ន្ធនឹងសំណុំរឿង០០២/០២ និងអាចបញ្ជាក់អំពីភាពជឿជាក់បាននៃដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ ស្នាមមេដៃរបស់ មាន លឿយ មាននៅលើទំព័រនីមួយៗនៃពាក្យសុំ។ ជាងនេះទៀត មិនមានការសង្ស័យណាមួយត្រូវបានលើកឡើងអំពីយថាភាពនៃពាក្យសុំនេះ ក្នុងអំឡុងពេលនៃ

ការផ្តល់សក្ខីកម្មរបស់គាត់ឡើយ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះពិចារណាឃើញថាលក្ខណៈវិនិច្ឆ័យនៃវិធាន ៨៧(៣) និង (៤) នៃវិធានផ្ទៃក្នុង ត្រូវបានបំពេញ ហើយអង្គជំនុំជម្រះសម្រេចទទួលយកឯកសារនេះ។

៧. ផ្ទុយទៅវិញ ឯកសារ E319/25.3.24 ជាកម្មសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីមួយរូប ដែលសក្ខីកម្មរបស់គាត់ត្រូវបានលុបចោល ហើយសហមេធាវីនាំមុខលែងស្នើសុំសំអាងលើឯកសារនេះទៀតហើយ។ ថ្វីដ្បិតស្នាមមេដៃរបស់អ្នកដាក់ពាក្យសុំមាននៅលើពាក្យសុំក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេតពុំទាន់បានសម្រេចអំពីភាពជឿជាក់បាននៃពាក្យសុំនេះ ឬ យថាភាពនៃពាក្យសុំនេះនៅឡើយ ដោយហេតុថាពាក្យសុំនេះពុំទាន់ត្រូវបានទទួលយកនៅក្នុងសំណុំរឿង ០០៤ នោះទេ (ឯកសារ E319/14/2, កថាខណ្ឌ ៤)។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះបដិសេធចំពោះ ឯកសារ E319/25.3.24 ។

៨. អនុស្សារណៈនេះ គឺជាចម្លើយតបផ្លូវការរបស់អង្គជំនុំជម្រះ ទៅនឹងសំណើ E319/31។